**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីជូនដំណឹង
# ស្តីពីការកែតម្រូវពាក្យពេចន៍ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រីមាសទី២ ឆ្នាំ២០២០ ជាភាសាខ្មែរ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាបថា៖ របាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០២០ ជាភាសាខ្មែររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ដែលបានធ្វើការផ្សព្វផ្សាយនៅលើគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ មានកំហុសខុសឆ្គងលើការបកប្រែពាក្យពេចន៍មួយឃ្លា នៅទំព័រលេខ ៩, ១០, ១១ និង១២ ត្រង់ចំណុច *"នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ ៦ខែ"* ។

អាស្រ័យហេតុនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក សូមធ្វើការកែតម្រូវឡើងវិញនូវពាក្យពេចន៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០២០ ជាភាសាខ្មែរដូចខាងក្រោម៖

១. នៅទំព័រលេខ ៩, ១១ និងលេខ១២ ឃ្លា *"នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ ៦ខែ"* ត្រូវបានលុបចោល ហើយកែតម្រូវទៅជា *"សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៦ខែ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០"* វិញ។

២. នៅទំព័រលេខ ១០ ឃ្លា *"នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ ៦ខែ"* ត្រូវបានលុបចោល ហើយកែតម្រូវទៅជា *"សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៣ខែ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០"* វិញ។

ដោយឡែកព័ត៌មានផ្សេងៗទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០២០ ជាភាសាខ្មែរ នៅរក្សាដដែល។

សូមភ្ជាប់ជូនមកជាមួយនូវ *របាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០២០ ជាភាសាខ្មែរ ដែលបានកែតម្រូវរួចរាល់* ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១០ រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក**